# សហគមតេហ្សេ TAIZÉ

*សារលិខិតសម្រាប់ឆ្នាំ ២០២៣*

# ជីវិតខាងវិញ្ញាណ និងភាពសាមគ្គី

តើយើងអាចបង្កើតមេត្រីភាព រវាងមនុស្សទាំងឡាយ ព្រមទាំងរវាងមនុស្សនិងធម្មជាតិ ដោយពឹងលើអ្វី? សាសនានានាជាចម្លើយមួយ ដែលប្រជាជនលើផែនដីបានចងក្រង។

គ្រីស្តបរិស័ទគួររិះគិតអំពីជំនឿផ្ទាល់ ឲ្យស៊ីជម្រៅ តែមិនមែនដើម្បីអួតខ្លួនថា យល់សព្វគ្រប់នូវអ្វីៗទាំងអស់នោះទេ។ ផ្ទុយទៅវិញ គ្រីស្តបរិស័ទត្រូវរកផ្លូវតបឆ្លើយ រួមជាមួយអស់អ្នកដែលមិនព្រមគិតថា ការប្រឈមមុខនាបច្ចុប្បន្នជាព្រហ្មលិខិតនោះទេ។ សារឆ្នាំ២០២៣នេះចង់ផ្តល់យោបល់ ឲ្យយើងកែរបៀបរស់នៅជាគ្រីស្តបរិស័ទ ឲ្យសមនឹងសម័យ។

«អធិដ្ឋាន ហើយធ្វើអ្វីដែលជាអំពើសុចរិត»៖ នេះជាគំនិតរបស់លោកគ្រូគង្វាល **ឌៀទ្រីស បុនហឺហ្វ៊ែរ** Dietrich Bonhoeffer (១៩០៦-១៩៤៥) ពេលជាប់ក្នុងមហាន្តរាយនៃសង្គ្រាមពិភពលោកលើកទី២។ ក្នុងគុក គាត់រិះគិតអំពីខ្លឹមសារនៃជីវិតជាគ្រីស្តបរិស័ទ។ ក្នុងយប់អន្ធការនៃសម័យនោះ គាត់សរសេរយ៉ាងច្បាស់ថា៖ «ថ្ងៃនេះ យើងអាចសង្ខេបជីវិតជាគ្រីស្តបរិស័ទ តាមឥរិយាបថពីរប៉ុណ្ណោះ គឺអធិដ្ឋាន ហើយធ្វើអំពើសុចរិតក្នុងចំណោមមនុស្ស។ អ្វីៗទាំងអស់ ដែលយើងគិត និយាយ និងធ្វើ ដើម្បីអនុវត្តជំនឿ ត្រូវតែចេញពីការអធិដ្ឋាន និងការប្រតិបត្តិ»។

តើពាក្យរបស់លោកមានអត្ថន័យអ្វីសម្រាប់យើង? យើងម្នាក់ៗអាចមានយោបល់ប្លែកៗពីគ្នា។ នៅភូមិតេហ្សេ យើងមានគំនិតថា គួរឲ្យយើងយល់ពីជីវិតខាងវិញ្ញាណច្បាស់ជាង និង

បណ្ដុះភាពសាមគ្គីឲ្យកាន់តែខ្លាំង ឬមួយ គួរឲ្យយើងយកចិត្តទុកដាក់អធិដ្ឋាន និងបង្កើតចំនង មេត្រីកាន់តែរឹងមាំជាមួយអ្នកដទៃ...

ដើម្បីឃើញសញ្ញានៃវត្តមានព្រះជាម្ចាស់ក្នុងជីវិត សក្ខីភាពលោក **ដៀទ្រីស បុនហ៊ើហ្វឺរ** អាចជួយយើងបាន។ គាត់យល់ច្បាស់ណាស់អំពីវិបត្តិសម័យ ក៏ប៉ុន្ដែដោយពឹងលើកម្លាំងចិត្ត គាត់បានជ្រើសរើសប្រកាន់សេចក្ដីសង្ឃឹម និងការជឿទុកចិត្តលើព្រះជាម្ចាស់ កុំឲ្យអស់សង្ឃឹម ចំពោះមនុស្សលោក ដូចមានមនុស្សជាច្រើនធ្លាប់បានប្រព្រឹត្ត ក្នុងសភាពប្រកបដោយហឹង្សា រហូតមកទល់សព្វថ្ងៃនេះផង។

ស្ថានភាពបច្ចុប្បន្នទាមទារឲ្យយើងជ្រើសរើសសេចក្ដីសង្ឃឹមដែរ។ យើងនៅតែមានសេរីភាព ដើម្បីរកក្នុងពិភពយើង ពន្លឺមួយដែលមកពីចម្ងាយ។ សូម្បីតែពេលយើងកំពុងរងទុក្ខលំបាក ឬសូម្បីតែពេលព្រះជាម្ចាស់ហាក់បីមិនតបឆ្លើយដល់សម្រែករបស់យើង ពន្លឺនោះនៅតែរះឡើង ដូចជាផ្កាយព្រឹកម៉្យាង ហើយស្ថិតក្នុងចិត្តរបស់យើង (២ សិលា ១,១៩)។

*បងប្រុស អាឡូអ៊ីស*

# ជ្រើសរើសសេចក្តីសង្ឃឹម

សព្វថ្ងៃនេះ មានបញ្ហាជាច្រើនសង្កត់ទៅលើយុវជនយុវនារី និងមនុស្សឯទៀតៗ៖ តើមានអ្វីអាចនាំឲ្យយើងមានសេចក្តីសង្ឃឹម ដើម្បីច្នៃប្រឌិតផ្លូវថ្មី? ពិតមែន មានមូលហេតុជាច្រើនដែលអាចបង្កឲ្យមានភាពតាន់តឹង និងធ្វើឲ្យយើងព្រួយបារម្ភអំពីអនាគតរបស់ផែនដី និងផ្ទាល់ខ្លួន។ អ្នកខ្លះក៏លែងជឿលើព្រះជាម្ចាស់ដែរ។

ការព្រួយបារម្ភជាប្រតិកម្មចិត្តត្រឹមត្រូវ ដែលធ្វើឲ្យភ្នែកមុត និងប្រជ្ញាឆ្លាតវៃ ហើយដូច្នេះអាចជួយសង្គ្រោះខ្លួនឲ្យផុតពីគ្រោះថ្នាក់។ ទោះជាយ៉ាងណា យើងត្រូវប្រយ័ត្ន កុំឲ្យចុះចាញ់អារម្មណ៍អវិជ្ជមាន ដូចជា ការអស់កម្លាំង ការភ័យក្លាច ឬការមានចិត្តរឹងចចេសចំពោះអ្នកដទៃ។

ដើម្បីកុំឲ្យយើងធ្លាក់ក្នុងអន្ទាក់ទាំងនេះ ព្រះបន្ទូលដំណឹងល្អបើកផ្លូវមួយ ដោយបង្ហាញព្រះយេស៊ូគ្រីស្តឲ្យយើង។ ព្រះអង្គដើរខាងមុខយើង។ អស់មួយជីវិត ព្រះអង្គបានស្គាល់ ទាំងអំណរសប្បាយ ទាំងការព្រួយបារម្ភ។ មនុស្សកាន់តែច្រើនបានប្រឆាំងនឹងព្រះអង្គ រហូតដល់ឈើឆ្កាង ជាទីឃោរឃៅបំផុត។ ក៏ប៉ុន្តែ សេចក្តីស្លាប់មិនបានឈ្នះទេ ពីព្រោះព្រះជាម្ចាស់បានលើកព្រះយេស៊ូ ឲ្យមានព្រះជន្មរស់ឡើងវិញ គឺព្រះជន្មអស់កល្បជានិច្ច។ នេះជាដំណឹងល្អដ៏អស្ចារ្យ។ សាវ័កដែលជាសាក្សីមុនដំបូងរបស់ព្រះអង្គ ក៏អញ្ជើញយើងឲ្យមានចិត្តក្លាហាន និងជឿទុកចិត្តទៅលើព្រះបន្ទូលរបស់ព្រះអង្គនេះ។

បច្ចុប្បន្ននេះ ព្រះគ្រីស្តនៅតែបន្តធ្វើដំណើរជាមួយមនុស្សម្នាក់ៗ ដើម្បីប្រោសគេឲ្យទទួលយកសេចក្តីស្រឡាញ់ឥតព្រំដែន របស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណដ៏វិសុទ្ធជាដង្ហើមរបស់ព្រះអង្គផ្តល់ឲ្យយើងមានកម្លាំងតស៊ូ ព្រមទាំងប្រទានតម្លៃដល់មនុស្ស ដែលគ្មានអ្វីអាចលប់បាន។

ចូរកុំឲ្យព្រឹត្តិការណ៍ខាងក្រៅបំភ័យយើង ផ្ទុយទៅវិញ សូមទទួលពន្លឺ ដែលគង់នៅក្នុងខ្លួនពោលគឺការទុកចិត្ត ដែលគេហៅថា«ជំនឿ»។

# អធិដ្ឋានដើម្បីស្វែករកប្រភពមួយ

បើសិនជាយើងចង់ដូរគំនិត អំពីជីវិតយើងផ្ទាល់ អ្នកដទៃ ក៏ដូចជាពិភពលោក យើងត្រូវតែរកវិធីសាស្ត្រផ្ទាល់ខ្លួនមួយ ដើម្បីធ្វើបាន។ វិធីសាស្ត្រនោះកើតចេញពីទីជម្រៅបំផុតនៃចិត្ត ជាកន្លែងដែលវត្តមានដ៏សប្បុរសរបស់ព្រះជាម្ចាស់គង់នៅ។ ពេលយើងបែរខ្លួនមករកព្រះជាម្ចាស់វិញ យើងនឹងកែប្រែចិត្តគំនិត គឺយើងព្រមទទួលព្រះហឫទ័យអាណិតអាសូររបស់ព្រះអង្គ ហើយក៏ចេះស្រឡាញ់កាន់តែខ្លាំងឡើងៗផង។

យើងទាំងអស់គ្នាគួររកកន្លែងនិងពេលវេលា ដើម្បីមានបទពិសោធន៍អំពីភាពស្ងប់ស្ងាត់ក្នុងចិត្ត ឲ្យចេះស្តាប់ និងយល់ឃើញថាព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យផ្សះផ្សាជាមួយយើង។ ព្រះយេស៊ូអញ្ជើញមិត្តព្រះអង្គថា៖ «កាលណាអ្នកអធិដ្ឋាន ត្រូវចូលទៅក្នុងបន្ទប់ បិទទ្វារឲ្យជិត ហើយទូលទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីស្ងាត់កំបាំង» (ម៉ាថាយ ៦,៦)។

សព្វថ្ងៃ ពាក្យអំពាវនានេះបញ្ច្រាស់នឹងទំនោរសង្គម។ យើងកំពុងឆ្លងកាត់សម័យ ដែលមនុស្សកាន់តែបែកបាក់គ្នានិងប្រឆាំងគ្នា សូម្បីតែក្នុងគ្រួសារ ព្រះសហគមន៍ និងក្រុមជំនុំ។ ក្នុងបរិយាកាសបែបនេះ សម្លេងឡូឡានិងពាក្យកុហកមានប្រៀបទៅលើគំនិត ដែលត្រូវការពេលវេលាយូរ ដើម្បីបន្ទុំខ្លួនក្នុងភាពស្ងប់ស្ងាត់។

ការអធិដ្ឋានមានសេចក្តីចាំបាច់រិតតែខ្លាំងជាងហ្នឹងទៅទៀត។ ការអធិដ្ឋានជាប្រភពនៃសេចក្តីសង្ឃឹម ជាផ្លូវនាំឲ្យចិត្តបានសុខសាន្ត ជាវិធីជួយពង្រឹងសមត្ថភាពដើម្បីសន្ទនាជាមួយមនុស្សទាំងអស់ ទាំងអ្នកដែលប្រឆាំងប្រកែកនឹងយើង ព្រមទាំងអ្នកដែលប្លែកពីយើងតែម្តង។

# ធ្វើដំណើររួមជាមួយគ្នា

លើសពីការអធិដ្ឋានម្នាក់ឯង ព្រះជាម្ចាស់ត្រាស់ហៅយើង ឲ្យធ្វើដំណើររួមជាមួយគ្នា ដើម្បីកសាងភាតរភាពសាកល ដែលយើងនៅតែចង់រកសញ្ញាសម្គាល់ឃើញ ក្នុងលោក។ ជីវិតខាងវិញ្ញាណមិនមានបំណង ឲ្យយើងរកតែឯកឯង។ ផ្ទុយទៅវិញ ជីវិតខាងវិញ្ញាណជាដំណើរដែលយើងធ្វើរួមជាមួយអស់អ្នក ដែលមានបំណងដូចគ្នា។

ដូច្នេះ គួរឲ្យយើងចាប់ផ្ដើមដំណើរនេះ ដោយរឹតបន្តឹងឯកភាព រវាងនិកាយទាំងប៉ុន្មាននៃគ្រីស្ដសាសនា គឺមិនមែនដើម្បីមានកម្លាំងប្រឆាំងនឹងពិភពលោក តែផ្ទុយទៅវិញ ដើម្បីឲ្យព្រះបន្ទូលដំណឹងល្អមានកម្លាំងប៉ះដល់បេះដូងរបស់មនុស្ស។ ដើម្បីធ្វើបាន ចូរឲ្យយើងទាំងអស់គ្នាជួបជុំគ្នាដើម្បីអធិដ្ឋានជាមួយគ្នា គឺមិនបាច់រង់ចាំដល់ពេលដែលគ្មានឧបសគ្គខាងលទ្ធិទៀតទេ។

ពេលណានិកាយផ្សេងៗមកដើម្បីជួបជាមួយគ្នា យើងឃើញថា ជំហររបស់ក្រុមនីមួយៗឃ្លាតឆ្ងាយពីគ្នា ពិបាកបង្រួមវិញ។ ដូច្នេះ សូមកុំមើលតែដល់គម្លាតទាំងអស់នោះ គឺសូមជ្រើសរើសធ្វើតាមរបៀបផ្សេងមួយទៀត៖ សូមចាប់ផ្ដើមដោយអធិដ្ឋាន រួមជាមួយគ្នា គ្រប់ពេលវេលាផង។ មានតែការអនុវត្តន៍ឯកភាពបែបនេះ ដែលនឹងផ្ដល់ ឲ្យប្រជាជនរបស់ព្រះជាម្ចាស់អាចប្រកាសជំនឿរួមជាមួយគ្នាបាន។

ប្រហែលវិធីនេះនឹងជួយយើងឲ្យកែប្រែគំនិត ដែលយើងគិតអំពីព្រះសហគមន៍ឬក្រុមជំនុំ គឺគួរយល់កាន់តែច្បាស់ថា ព្រះសហគមន៍ (ឬក្រុមជំនុំ) ជាមហាគ្រួសាររបស់អស់អ្នក ដែលបានជ្រើសរើសសេចក្ដីស្រឡាញ់ តាមព្រះគ្រីស្ដ។ បើយើងចង់ទៅជាមេម្បៅនៃសន្តិភាព យើងត្រូវបញ្ចប់គ្រប់ការបែកបាក់គ្នា ដែលបណ្ដាលឲ្យយើងដើរតាមផ្លូវពីរ ដែលទន្ទឹមគ្នា ហើយមិនចេះជួបគ្នាសោះ។

ការស្វែងរកឯកភាពរវាងនិកាយទាំងឡាយជាឱកាស ដើម្បីទទួលស្គាល់អំពើអាក្រក់ដែលក្រុមនីមួយៗធ្លាប់បានប្រព្រឹត្ត ព្រមទាំងខិតខំយ៉ាងមឹងម៉ាត់ ឲ្យមានការផ្លាស់ប្ដូរដែលចាំបាច់។ មនុស្សជាច្រើនបាត់ការទុកចិត្ត ហើយសូម្បីតែនៅតែហ្បេ ក៏អ្នកខ្លះបានទៅជាជនរងគ្រោះដែរ។ ការទុកចិត្តគ្នាពិបាកកសាងសាឡើងវិញ គឺអាចធ្វើបាន លុះត្រាតែយើងចេះស្ដាប់ចំពោះបងប្អូនដែលត្រូវបានរងរបួសនោះ។

# ពង្រីកមេត្រីភាព

ដើម្បីកសាងភាតរភាពសាកលនេះ ព្រះសហគមន៍(ឬក្រុមជំនុំ) ត្រូវធ្វើបន្ទាល់អំពីព្រះរាជ្យនៃព្រះជាម្ចាស់ ដែលកំពុងតែយាងមក ហើយក៏ត្រូវយល់អំពីការត្រាស់ហៅរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ខ្លួនផ្ទាល់ ក្នុងសម័យបច្ចុប្បន្ននេះ។ នេះជាការត្រាស់ហៅខ្លះៗ ដែលយើងរួមជាមួយគ្នាគួរចាប់អារម្មណ៍៖

- សម្រាប់មនុស្សជាច្រើន អារម្មណ៍ជាសមាជិកក្នុងក្រុមមួយមានសារសំខាន់ខ្លាំងណាស់ ដើម្បីជួយគេកសាងអត្តសញ្ញាណផ្ទាល់។ ក៏ប៉ុន្តែ អារម្មណ៍នោះមិនគួររីកចម្រើនឡើង ដោយពឹងលើការប្រឆាំងជំទាស់ តែផ្ទុយទៅវិញ ដោយពឹងលើការគោរពគ្នា និងលើការជួបជុំគ្នា។ ពេលណា យើងខំរកសេចក្ដីពិតរបស់អ្នកដទៃពេលនោះ យើងក៏មានការរីកចម្រើនដែរ។
- ការសន្ទនារវាងសាសនានានា អាចជួយយើង ឲ្យចេះគោរពគ្នាទៅវិញទៅមក។ ពេលណាយើងនិយាយជាមួយគ្នា យើងអាចមានចិត្តទូលំទូលាយ លុះត្រាតែយើងមានការយល់យ៉ាងស៊ីជម្រៅអំពីសាសនារបស់យើងផ្ទាល់ ដូចដើមឈើត្រូវការមានឫសយ៉ាងជ្រៅ ដើម្បីឲ្យមែករបស់វាបើកចំហ។ មេត្រីភាពពិតប្រាកដអាចកើតបាន ទោះបីយើងត្រូវឈឺចាប់បន្តិច ពីព្រោះអ្នកដទៃមិនអាចទទួលគំនិតរបស់យើងទាំងស្រុងនោះបានទេ។

- បងប្អូនជាច្រើនពិបាកចិត្តដោយឃើញថា ការប្រកាន់ជាតិសាសន៍ និងគំនិតរើសអើងគ្រប់បែបយ៉ាង បានធ្វើជាឧបសគ្គ មិនអនុញ្ញាតឲ្យមានទំនាក់ទំនងស្រួលបួលរវាងបុគ្គល និងនៅក្នុងសង្គម។ ដូច្នេះ ចូររកវិធីមួយ ដើម្បីដូរចិត្តគំនិតរបស់យើងចំពោះអ្នកដទៃ ឧ. ដោយយើងខិតខំស្ដាប់ជនអន្តោប្រវេសន៍ ដែលត្រូវចាកចេញពីស្រុកកំណើត... ហើយពេលយើងជួបនឹងអ្នកដទៃ ចូរយើងទទួលយកភាពខុសគ្នារបស់គេ ទុកដូចជាទ្រព្យសម្បត្តិមួយ។
- តើយើងចេះស្ដាប់សម្រែកនៃផែនដីរបស់យើង? ជាញឹកញាប់ សកម្មភាពយើងនិងការធ្វេសប្រហែស បំផ្លាញភពដ៏អស្ចារ្យរបស់យើង បណ្ដាលឲ្យមានគ្រោះធម្មជាតិ និងបាតុភូតធាតុអាកាសកាន់តែច្រើន។ មនុស្សលោកត្រូវនឹកពីការទទួលខុសត្រូវដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេ។ តួយ៉ាងខាងនយោបាយនិងសេដ្ឋកិច្ចត្រូវយកសេចក្ដីសម្រេចជាចាំបាច់។ ក៏ប៉ុន្តែ យើងផ្ទាល់អាចធ្វើឲ្យរបៀបរស់នៅរបស់ខ្លួនសាមញ្ញជាង និងឲ្យយើងចេះកោតសរសើរព្រះជាម្ចាស់ ចំពោះធម្មជាតិដែលជាស្នាព្រះហស្ដរបស់ព្រះអង្គ។
- សង្គ្រាមនៅអ៊ុយក្រែន និងតាមតំបន់ជាច្រើនក្នុងលោក នាំឲ្យមនុស្សមួយចំនួនគិតថា គ្មានព្រះជាម្ចាស់ទេ ឬថា ព្រះអង្គចេះតែនៅស្ងៀម ដូច្នេះគេពិបាកអធិដ្ឋាន។ តាមពិត ពេលណាយើងអធិដ្ឋានសូមសន្តិភាព យើងដូចជាសុខចិត្តទទួលខុសត្រូវ និងចូលរួមសាមគ្គី ជាមួយមនុស្សទាំងអស់ ដែលជាជនរងគ្រោះនៃសង្គ្រាម។ យើងមិនសូមព្រះជាម្ចាស់ប្រទានសន្តិភាព ដោយផ្ដល់ជោគជ័យដល់ភាគីឃោរឃៅ តែផ្ទុយទៅវិញ សន្តិភាពពិតប្រាកដនិងយូរអង្វែង ក៏ពឹងលើយុត្តិធម៌និងសេចក្ដីពិត។ មែនហើយ! អធិដ្ឋានសម្រាប់សន្តិភាពជាកាតព្វកិច្ចបន្ទាន់ជាងគេ។

ចំពោះបងប្អូនដែលជាអ្នកជឿលើព្រះជាម្ចាស់ ជំនឿអាចផ្ដល់សេចក្ដីសង្ឃឹមខ្លាំងជាងការភ័យខ្លាចអំពីអនាគត។ ជំនឿនេះមិនមែនជាការទុកចិត្តភ្លើតភ្លើននោះទេ តែផ្ទុយទៅវិញជាការជឿជាក់ថា ព្រះជាម្ចាស់កំពុងតែសកម្ម នៅលើផែនដីនេះ ដែលជាស្នាព្រះហស្ដរបស់ព្រះអង្គ

ហើយ ទ្រង់ក៏ត្រាស់ហៅយើង ឲ្យចូលរួមចំណែកសកម្មជាមួយព្រះអង្គ គឺឲ្យចេះទទួលខុសត្រូវសម្រាប់ជំនាន់ឥឡូវ និងជំនាន់ក្រោយ។

ពេលណាយើងឃើញថា មិនអាចមានសន្តិភាពបានទេ ដោយសារហឹង្សាធ្វើឲ្យជនជាតិនានាបែកបាក់គ្នា ព្រមទាំងឃើញគ្រោះគ្រប់បែបយ៉ាងធ្វើឲ្យផែនដីរង្គើ ពេលនោះបើយើងរួបរួមជាមួយបងប្អូនយើង ក្នុងសេចក្តីស្រឡាញ់កាន់តែខ្លាំង គឺព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏យាងមកគង់នៅជាមួយយើងដែរ សូម្បីតែជីវិតខាងវិញ្ញាណរបស់យើងទ្រុឌទ្រោមយ៉ាងណាក៏ដោយ។ ព្រះអង្គផ្លាស់ប្តូររបៀបដែលយើងធ្លាប់មើលដល់អ្នកដទៃ ទ្រង់ក៏អាចណែនាំយើងឲ្យធ្វើដំណើរទៅឆ្ងាយ គឺទ្រង់អញ្ជើញយើងឲ្យរំលងដែនកំណត់ បង្ហួសទៅកាន់ជីវិតថ្មី។ តើយើងចង់ទទួលព្រះអង្គដែរឬទេ?

បកប្រែដោយ លោកឪពុក ចេវ៉ាល នៅថ្ងៃទី ២៥/០១/២០២៣